**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ២៥៤៥ សហវ.អគ

ថ្ងៃសុក្រ ១១ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០២០

**សូមគោរពជូន**
**សម្តេច ឯកឧត្តម លោកជំទាវ ប្រធានគ្រប់ក្រសួង ស្ថាប័ន**
**អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ**

**កម្មវត្ថុ៖** គោលការណ៍នៃការអនុវត្តការផ្ទេរវិភាគទានស្ម័គ្រចិត្តពីបៀវត្សប្រចាំខែរបស់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការជូនមូលនិធិប្រយុទ្ធនឹងជំងឺកូវីដ ១៩ (COVID-19)។

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្តេច ឯកឧត្តម លោកជំទាវ ប្រធានគ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ** មេត្តាជ្រាបថា៖ដោយគោរពប្រតិបត្តិតាមគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, ឥស្សរជន ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ នៃក្រសួង ស្ថាប័នរដ្ឋ បាន និងកំពុងបន្ត ចូលរួមវិភាគទានយ៉ាងសកម្ម ជាការលះបង់នូវបៀវត្សផ្ទាល់ខ្លួន ជូនដល់មូលនិធិប្រយុទ្ធនឹងជំងឺកូវីដ ១៩ (COVID-19) ដើម្បីគោលដៅនៃការប្រយុទ្ធប្រឆាំង និងទប់ស្កាត់ការរីករាលដាល នៃជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ កូវីដ ១៩ (COVID-19) នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងស្មារតីសាមគ្គីជាតិ និងការចែករំលែកប្រកបដោយសណ្តានចិត្តសប្បុរសធម៌ និងបរិសុទ្ធ។ យ៉ាងណាមិញ, នៅក្នុងការអនុវត្តការងារផ្ទេរវិភាគទានស្ម័គ្រចិត្តនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពិនិត្យឃើញថា មានបញ្ហាស្មុគស្មាញផ្នែកបច្ចេកទេសមួយចំនួន ដោយបៀវត្សប្រចាំខែមីនា ត្រូវបានបង្វែរចូលគណនីធនាគារ និងបើកផ្តល់ជូនរួចរាល់អស់ហើយ។ ទន្ទឹមនេះ សម្រាប់បៀវត្សខែមេសា ដែលត្រូវធ្វើការបើកផ្តល់បៀវត្ស រួមជាមួយនឹងប្រាក់ឧបត្ថម្ភចំនួន ៥០ ០០០ រៀល ឱ្យបានមុនពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរនោះ ក៏ត្រូវបានផ្ទេរចូលគណនីផ្ទាល់ខ្លួន ឬ បើកផ្តល់ជូនមន្ត្រីរាជការមួយចំនួនធំរួចហើយដែរ។

ដូច្នេះ ដើម្បីសម្រួលដល់ការចូលរួមខាងលើ សូម **សម្តេច ឯកឧត្តម លោកជំទាវ ប្រធានគ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ** មេត្តាជូនដំណឹងដល់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ៖ (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

ដែលបានស្ម័គ្រចិត្តបរិច្ចាគបៀវត្សជូនមូលនិធិប្រយុទ្ធនឹងជំងឺកូវីដ ១៩ (COVID-19) អំពីគោលការណ៍នៃការអនុវត្តការផ្ទេរវិភាគទាននេះ ដូចតទៅ÷

ទី១- សម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការ ដែលមានគណនីបៀវត្សនៅធនាគារពាណិជ្ជដៃគូ ហើយអាចគ្រប់គ្រងសម្របសម្រួលបាន ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ, នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ នឹងសហការជាមួយក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំធ្វើការសម្រួលកាត់កង និងផ្ទេរវិភាគទាននេះដោយស្វ័យប្រវត្តិ ចូលទៅគណនីនៃមូលនិធិប្រយុទ្ធនឹងជំងឺកូវីដ ១៩ (COVID-19) ផ្អែកតាមលក្ខខណ្ឌនៃវិភាគទានស្ម័គ្រចិត្តពីបៀវត្សប្រចាំខែរបស់សាមីមន្ត្រីនីមួយៗ ដោយចាប់ផ្តើមរាប់ពីខែឧសភា ជាខែទីមួយ ទោះជាសាមីមន្ត្រីពាក់ព័ន្ធ បានប្រកាសចូលរួមវិភាគទានរាប់ពីខែមីនា ឬ ខែមេសា ជាខែទីមួយក៏ដោយ;

ទី២- ចំពោះថ្នាក់ដឹកនាំនិងមន្ត្រីដែលមិនមានគណនីបៀវត្សផ្ទាល់ខ្លួន (មន្ត្រីយោធា ឬ មន្ត្រីផ្សេងទៀត) ឬ មន្ត្រីដែលមានគណនីបៀវត្សផ្ទាល់ខ្លួន តែមិនស្ថិតនៅក្រោមការសម្របសម្រួលគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ (មន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ, គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, អាជ្ញាធរសវនកម្មជាតិ ជាដើម) គឺត្រូវចាត់ចែងផ្ទេរ ឬ យកវិភាគទានរបស់ខ្លួន ទៅបង់ដោយផ្ទាល់ជូនមូលនិធិប្រយុទ្ធនឹងជំងឺកូវីដ១៩ (COVID-19) តាមលក្ខខណ្ឌដែលខ្លួនបានស្ម័គ្រចិត្ត។

ក្នុងករណីមានចម្ងល់ សូមទាក់ទងមកអគ្គនាយកដ្ឋានរតនាគារជាតិ តាមរយៈទូរស័ព្ទលេខ ០១២ ៨៧៨១៧៧ និង ០១៧ ២៩១១២៥។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេច ឯកឧត្តម លោកជំទាវ ប្រធានគ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ** មេត្តាជ្រាប និងជូនដំណឹងមន្ត្រីរាជការក្រោមឱវាទរបស់ខ្លួនដែលបានស្ម័គ្រចិត្តបរិច្ចាគបៀវត្សជូនមូលនិធិប្រយុទ្ធនឹងជំងឺកូវីដ ១៩ (COVID-19) តាមយន្តការខាងលើ តាមការគួរ។

សូម **សម្តេច ឯកឧត្តម លោកជំទាវ ប្រធានគ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ ពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**